00603426

លេខ / No: D426

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 09 / 2010
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម **Marcel LEMONDE**

ឯកសារថតចម្លង
COPY/COPIE
ថ្ងៃ ខែ ឆ្នាំ (Date): 15-Sep-2010, 14:14
CMS/CFO: Kauv Keoratanak

កាលបរិច្ឆេទ ៖ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០

ភាសា ៖ ខ្មែរ/បារាំង

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

# ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាស័យដ្ឋាននៅក្នុងខេត្តកំពង់ចាម

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្កេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
 នី ចាន់ឌី
ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
ជេត វណ្ណលី
ពេជ អង្គ
វ៉ែន ពៅ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Ferdinand Djammen-Nzepa
Emmanuel ALTIT
Emmanuel JACOMY
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU
Pascal AUBOIN
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
Julien RIVET

**មេធាវីការពារក្តី**
សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស ស្វាន Jacques VERGÈS
Philippe GRÉCIANO
ការ សាវុត្ថ

00603427

០០២/១៩-០៩-២០០៧/អ.វ.ត.ក.-ក.ស.ច.ស. លេខ/No: D426

**យើង យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរលើឈ្មោះ នួន ជា និង ជនដទៃ ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញវិធាន១២ វិធាន១២ស្ទួន វិធាន២១ វិធាន២៣ វិធាន២៣ស្ទួន វិធាន២៣ស្ទួនពីរ វិធាន៤៩ វិធាន៥៣ វិធាន៥៥ វិធាន៥៦(២)(ក) វិធាន៦៦ និង វិធាន១០០ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញមាត្រា១ មាត្រា៣ និង មាត្រា៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ("សេចក្តីណែនាំអនុវត្ត")

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (D83), ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ (D98/I),ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ (D196), ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (D146/3), ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ (D202), ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (D146/4) និងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (D146/5)

បានឃើញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការស្នើសុំទាមទាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាព (E2/5/3)

បានឃើញសេចក្តីជូនដំណឹងដល់ភាគីអំពីការដាក់បញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងអនុលោមតាមវិធាន២៣ នៃវិធានផ្ទៃក្នុងចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ (D316)

បានឃើញសេចក្តីជូនដំណឹងរបស់យើងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ (D317)

បានឃើញអនុស្សរណៈរបស់យើងស្តីអំពីការដាក់ពាក្យបណ្តឹងធម្មតានិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ (D337)

បានឃើញអនុស្សរណៈអន្តរការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតទៅអង្គភាពគាំពារជនរងគ្រោះពន្យាពេលវេលាកំណត់សម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ (D337/1)

បានឃើញអនុស្សរណៈអន្តរការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាពេលវេលាកំណត់សម្រាប់ដាក់ព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ (D337/6)

បានឃើញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០(D364/1/3) និងថ្ងៃ ទី២៧ ខែមេសា ឆ្នាំ២០១០ (D250/3/2/1/s)

បានឃើញអនុស្សរណៈអន្តរការិយាល័យរបស់ក្រឡាបញ្ជីទាក់ទងនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព (D386)

បានឃើញដីកាសម្រេចស្តីពីការរៀបចំតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុវត្តតាមវិធាន២៣ ស្ទួនពីរនៃវិធានផ្ទៃក្នុង (D337/10)

00603429



បានឃើញសាលក្រមរបស់អង្គជំនុំជម្រះលើកាំង ហ្កេកអ៊ាវ ហៅ ឌុច (001/18-07-2007/ ECCC/TC)

បានឃើញចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើសុំរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនូវរយៈពេលពិសេសមួយសម្រាប់ប្រមូលនិងដាក់ព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥៦៩នាក់ដែលទើបបានចាត់តាំង (D337/11/1)

## I. **ការរំលឹកឡើងវិញអំពីនីតិវិធី:**

១. ក្នុងការអនុវត្តវិធាន២៣ស្ទួន (២) និង(៣)នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតនឹងសម្រេចតាមរយៈនៃដីកានេះ នូវភាពអាចទទួលយកបានទៅលើពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានចំនួន៣៩៨៨នាក់ (បីពាន់ប្រាំបួនរយប៉ែតសិបប្រាំបីនាក់)[១]។ ដោយពិចារណាលើតម្រូវការនៃការសម្របសម្រួលការជូនដំណឹង និងភាពតំណាងស្របច្បាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងធម្មតា សហចៅក្រមស៊ើបអង្កេតបានសម្រេចចេញដីកាសម្រេចលើភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកទៅលើទីលំនៅបច្ចុប្បន្នរបស់អ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹងដែលបានសរសេរនៅក្នុងទម្រង់បំពេញព័ត៌មានរបស់ពួកគេ។

២. សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា មានអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧០៦នាក់ (ប្រាំពីររយប្រាំមួយនាក់)[២] ដែលបានចាត់តាំងមេធាវីរួចហើយនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ មិនបានចាត់វិធានការដើម្បីផ្តល់នូវព័ត៌មានបន្ថែមមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ នោះទេ។ ជាមួយគ្នានេះផងដែរ អ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៩នាក់ (ដប់ប្រាំបួននាក់)ដែលបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋរប្បវេណីនៅក្នុងសំណុំរឿង០០១ (001/18-07-2007/ ECCC/TC) និងសំណុំរឿង០០២ (002/19-09-2007/ ECCC-OCIJ) ហើយដែលអ្នកទាំងនោះ ត្រូវបានប្រកាសជំរសេច ជាដើមបណ្តឹងរដ្ឋប្ប វេណីនៅក្នុងសំណុំរឿង ០០១ (001/18-07-2007/ECCC/TC)

[១] ចំនួននេះនឹងត្រូវបានកែប្រែវិញនៅពេលដែលមានការដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្រោយពីការចុះហត្ថលេខាលើដីកានេះ។

[២] ឧបសម្ព័ន្ធ ឃ៖ (D337/10)

ដោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ បានស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្តងទៀតនៅក្នុងសំណុំរឿងបច្ចុប្បន្នដោយដាក់នូវព័ត៌មាន បន្ថែម។

៣. ដីកានេះទាក់ទងនឹងអ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៩១នាក់ **(បួនរយកៅសិបមួយនាក់)** ដែលបានដាក់ពាក្យបណ្តឹងដោយបុគ្គលដែលមានទីលំនៅ នៅពេលស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង**ខេត្តកំពង់ចាម**នៃព្រះរាជាណាចក្រកម្ពុជា និងដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេតតាមរយៈអង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.កស្របតាមវិធាន១២ស្ទួន(ខ)[៣] ។ ក្នុងចំណោមអ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានអ្នកស្នើសុំចំនួន**២១២នាក់ (ពីររយដប់ពីរនាក់)** បានផ្តល់ព័ត៌មានបន្ថែមដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដំបូងរបស់ពួកគេមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០។ ដីកានេះនឹងយោងដល់ព័ត៌មានចាំបាច់ដាច់ខាតទៅលើអ្នកសុំតាំងខ្លួនជាដើមបណ្តឹងនីមួយៗតែប៉ុណ្ណោះ[៤]។

៤. សហចៅក្រមស៊ើបអង្កេតបានទទួលព័ត៌មានទាក់ទងនឹងមរណភាពរបស់៖

ក) អ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ08-VU-01340 (D22/1331), 09-VU-00344 (D22/1732), និងលេខ 09-VU-03422 (D22/2417) តាមរយៈរបាយការណ៍វាយតម្លៃទៅលើហានិភ័យដែលបានដាក់មកដោយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ។

ខ) អ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ07-VU-00016 (D22/1272)តាមរយៈប្អូនស្រីរបស់គាត់ដែលបានផ្តិតមេដៃបញ្ជាក់ពីមរណភាព និងបានស្នើសុំបញ្ចប់បណ្តឹងរដ្ឋប្បវេណី។

គ) អ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ08-VU-00740 (D22/2634) តាមរយៈកូនស្រីរបស់គាត់ ដែលបានបញ្ជាក់ពីមរណភាព និងស្នើសុំបញ្ចប់បណ្តឹងរដ្ឋប្បវេណី។

---

[៣] ឧបសម្ព័ន្ធ១៖ ពាក្យសុំតាំងខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់មកសហចៅក្រមស៊ើបអង្កេត

[៤] អង្គភាគាំពារជនរងគ្រោះបានដាក់មកនូវរបាយការណ៍ផ្ទាល់ខ្លួនសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដោយរួមមានទាំងការរៀបរាប់ជាសង្ខេបនូវអង្គហេតុជាភាសាអង់គ្លេស។ របាយការណ៍ទាំងអស់នេះត្រូវបានដាក់ចូលក្នុងសំណុំរឿងរួចហើយ។

II- **សំអាងហេតុនៃសេចក្តីសម្រេច**

៥. យោងតាមវិធានផ្ទៃក្នុង"ជនរងគ្រោះ"គឺជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការនៃអ.វ.ត.ក។ គ្រប់ជនរងគ្រោះទាំងអស់អាចដាក់ពាក្យប្តឹងទៅសហព្រះរាជអាជ្ញាស្របតាមវិធាន៤៩(២)។ ចំពោះ"ភាគីដើមបណ្តឹងរដ្ឋប្បវេណី"វិញ ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវឲ្យនិយមន័យថាជាជនរងគ្រោះដែលពាក្យសុំតាំងខ្លួនរបស់ពួកគេត្រូវ ប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬក៏អង្គបុរេជំនុំជម្រះ។

៦. វិធាន២៣ (១) នៃវិធានផ្ទៃក្នុងបានចែងថា គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺដើម្បី៖

ក) ចូលរួមក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង

ខ) អនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាពដែលមានចែងក្នុងក្នុងវិធាននេះ។

៧. ដូច្នេះ ដើម្បីឲ្យជនរងគ្រោះអាចត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងបច្ចុប្បន្ន(ដែលខុសពីអ្នកប្តឹងធម្មតា) ជនរងគ្រោះត្រូវតែបង្ហាញថាខ្លួនមានផលប្រយោជន៍ក្នុងការប្តឹង។

**ក- គោលការណ៍ណែនាំសំខាន់ៗ**

៨. នៅចំពោះមុខ អ.វ.ត.ក បណ្តឹងរដ្ឋប្បវេណីគឺត្រូវបើកចំហរដល់ជនរងគ្រោះទាំងឡាយណាដែលអាចបង្ហាញយ៉ាងជាក់ច្បាស់ថា ពួកគាត់ពិតជាបានទទួលរងព្យសនកម្មដោយផ្ទាល់ដល់រូបរាងកាយ សម្ភារៈ ឬផ្លូវចិត្តដែលបង្កឡើងដោយផ្ទាល់យ៉ាងហោចណាស់ ក៏ពីអំពើឧក្រិដ្ឋមួយក្នុងចំណោមអំពើឧក្រិដ្ឋទាំងឡាយដែលបានចោទប្រកាន់ទៅលើជនត្រូវចោទ មានន័យថាអង្គហេតុដែលមានលក្ខណៈជាបទល្មើសនោះត្រូវស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

i) **ការិតនៃតស្តុតាង និងព័ត៌មានគ្រប់គ្រាន់**

៩. វិធាន២៣ ស្ទួន(១) និង(៤)នៃវិធានផ្ទៃក្នុង និងមាត្រា៣.២ នៃសេចក្ដីណែនាំអនុវត្តបានចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី *"ត្រូវតែមានព័ត៌មានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្ដឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ។ ជាពិសេសពាក្យបណ្ដឹងត្រូវផ្ដល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់"*ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតដែលទទួលពាក្យបណ្ដឹងអាច *"ជឿថាអង្គហេតុដែលបានលើកឡើងសំរាប់គាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានកើតមានឡើងពិតប្រាកដ"*។ កម្រិតនៃភស្តុតាងគឺមានលក្ខណៈពិសេសសំរាប់បណ្ដឹងរដ្ឋប្បវេណី និងដែលមានលក្ខណៈខុសគ្នាពីសញ្ញាណនៃភស្តុតាងគ្រប់គ្រាន់ដូចមានចែងក្នុងវិធាន៦៧ (៣)(គ)។

១០. សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា នៅដំណាក់កាលស៊ើបសួរខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចអំពីលក្ខណៈពិតប្រាកដនៃព្យសនកម្មដែលបានចោទប្រកាន់ដោយជនរងគ្រោះឡើយ។ ក្នុងករណីចាំបាច់ សេចក្ដីសម្រេចអាចធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលចេញសាលក្រមលើអង្គសេចក្ដីរបស់ខ្លួន ដោយផ្អែកទៅលើបណ្ដុំនៃភស្តុតាងដែលលើកឡើងនៅពេលសវនាការ[៥]។ ដូច្នេះ ដើម្បីឱ្យពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវទទួលស្គាល់បាន សហចៅក្រមស៊ើបអង្កេតត្រូវមានលទ្ធភាពគ្រប់គ្រាន់ក្នុងការវាយតម្លៃ (ដោយយោងទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង) ថាតើវាពិតជាមានមូលដ្ឋានដែលអាចជឿជាក់ជាបឋមថាពិតជាមានព្យសនកម្មដូចបានលើកឡើង និងពិតជាមានទំនាក់ទំនងផ្ទាល់រវាងព្យសនកម្មនេះ ជាមួយនឹងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបសួរ។

១១. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថាបរិបទ និងវិសាលភាពនៃការស៊ើបសួរនៅក្នុងសំណុំរឿង០០២/១៩-០៩-២០០៧ (002/19-09-2007-ECCC-OCIJ) គឺជួនកាលមានការលំបាក

[៥] មើលជាអាទិ៍ យុត្តិសាស្ត្ររបស់តុលាការកំពូលនៃប្រទេសបារាំងថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៩៦ (**Cass.crim. 4 juin 1996**), យុត្តិសាស្ត្រថ្ងៃទី ៥ ខែមិនា ឆ្នាំ១៩៩០ (***Cass. crim. 5 mars 1990*** : Crim. 16 juin 1998, Bull. n° 191 ***Bull. crim. 1990, n° 103)*** យុត្តិសាស្ត្រថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩( **Crim. 16 févr. 1999, Bull. n° 17)** យុត្តិសាស្ត្រថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០០២ ( ***Cass. crim., 19 févr. 2002 : Bull. crim. 2002, n° 34.)*** យុត្តិសាស្ត្រថ្ងៃទី ២ ខែមេសា ឆ្នាំ២០០៣ ( ***Cass. crim., 2 avr. 2003 : Bull. crim. 2003)*** ដូចគ្នាផងដែរ យុត្តិសាស្ត្ររបស់សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិរឿង លុយបាហ្គា (***Lubanga )*** ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨ កឋាខណ្ឌ ទី៩៩ និងសាលក្រមរបស់កាំងហ្កេចអ៊ាវ ហៅឌុច របស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ កឋាខណ្ឌទី៦៣៦។

និងជួនកាលមិនអាចតែម្តងក្នុងការទាមទារឱ្យជនរងគ្រោះផ្តល់ភស្តុតាងសម្រាប់គាំទ្រដល់ពាក្យសុំរបស់ខ្លួន។ សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថាពាក្យសុំភាគច្រើនធ្វើឡើងដោយបុគ្គលដែលបានឆ្លងកាត់របប ឬព្រឹត្តការណ៍នោះ ដែលនៅក្នុងដែនសមត្ថកិច្ចពេលវេលារបស់ អ.វ.ត.ក មិនអាចអោយពួកគាត់ (អ្នកដាក់ពាក្យសុំ) ផ្តល់នៅភស្តុតាងជាសារវ័ន្តដែលអនុញ្ញាតឱ្យយើងធ្វើការពិនិត្យភាពសមស្របនៃពាក្យសុំ ជាមួយនឹងវិធានផ្ទៃក្នុងឡើយ។ នេះគឺជាការពិតដ៏ជាក់លាក់មួយសំរាប់ដើមបណ្តឹងដែលមានវ័យក្មេង នៅពេលដែលអង្គហេតុនោះកើតមានឡើង។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតរកឃើញថា ការស្រាវជ្រាវផ្នែកប្រជាសាស្ត្រដែលបានធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿងនេះបានបញ្ជាក់ថា *"ពុំមានការចងក្រងបញ្ជីឈ្មោះជនរងគ្រោះទេ (លើកលែងតែមន្ទីរស២១ និងត្រង់ចំនុចមួយចំនួនតូច)"* និងបញ្ជាក់ថា *"ប្រភពដែលទាក់ទងទៅនឹងស្ថិតិមរណភាព កំណើត និងជនអន្តោប្រវេសន៍ (នៅក្នុងប្រទេស និងនៅក្រៅប្រទេស) គឺមានលក្ខណៈនត្ថិភាព"*[៦] ។

១២. ម្យ៉ាងទៀត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបង្ហាញអំពីភស្តុតាងអំពីអត្តសញ្ញាណរបស់ពួកគេ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ក្នុងករណីមួយចំនួន ឯកសារអត្រានុកូលដ្ឋានជាផ្លូវការនៅកម្ពុជាការគឺមានការលំបាក ឬអាចមិនមាន។ ដូចនេះសហចៅក្រមយល់ឃើញថា ការពិនិត្យទៅតាមតថភាពជាក់ស្តែងគឺមានលក្ខណៈសមស្របបំផុតសម្រាប់បញ្ហានេះ[៧]។

១៣. លើសពីនេះ ដោយបានឃើញស្ថានការណ៍ដែលបានលើកឡើងដូចខាងលើ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថាភាគច្រើននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញពីការទទួលរងព្យសនកម្មផ្នែកផ្លូវចិត្ត មិនបានបង្ហាញភស្តុតាងអំពីទំនាក់ទំនងញាតិរបស់ពួកគេជាមួយនឹងជនរងគ្រោះនោះទេ។ ដូចគ្នាផងដែរ ក្នុងករណីមួយចំនួនសហចៅក្រមស៊ើបអង្កេតនឹងអនុវត្តសច្ចាធារណ៍នៃទំនាក់ទំនងញាតិដោយឈរលើមូលដ្ឋានការបំពេញបែបបទ និងឯកសារច្បាស់លាស់មួយចំនួនផ្សេងៗទៀតដែលបានដាក់ដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

---

[៦] របាយការណ៍អ្នកជំនាញប្រជាសាស្ត្រទំព័រ៩ និង២២ (D140/1/1)

[៧] ឯកសារជាច្រើនប្រភេទត្រូវបានចេញដោយអាជ្ញាធរដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ។ មើលផងដែរនូវសេចក្តីសម្រេចទាក់ទងនឹង **គាំង ហ្គេចអ៊ាវ ហៅ ឌុច** របស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក (E2/94)។

ii) **ការបង្ហាញព្យសនកម្ម**

១៤. ដើម្បីបង្ហាញពីប្រយោជន៍ក្នុងការប្តឹងរបស់ពួកគេ ជនរងគ្រោះដែលចង់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ បង្ហាញអត្ថិភាពនៃព្យសនកម្មលើរូបរាងកាយ សម្ភារៈ ឬផ្លូវចិត្ត[៨]ដែលបន្តដល់បច្ចុប្បន្នដល់សហចៅក្រមស៊ើបអង្កេត។ ចំពោះព្យសនកម្មផ្លូវចិត្ត សហចៅក្រមស៊ើបអង្កេតកត់សំគាល់ឃើញថា មាត្រា ៣.២នៃសេចក្តីណែនាំអនុវត្តន៍ចែងថា"*ការខូចខាតផ្លូវចិត្តអាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ*[៩] ។ ដូចនេះ ដើម្បីទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មដែលទទួលរងដោយអ្នកស្នើសុំមិនចាំបាច់ថាជាព្យសនកម្មផ្ទាល់នោះទេ ប៉ុន្តែវាត្រូវតែជាព្យសនកម្មដែលមានលក្ខណៈជាបុគ្គល[១០]។

១៥. ដើម្បីពិនិត្យថាមានព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គល សហចៅក្រមស៊ើបអង្កេតយល់ឃើញថា៖

ក) វាមានការសន្មតទុកជាមុននៃព្យសនកម្មខាងផ្លូវចិត្ត សំរាប់សមាជិកសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់[១១]។ ដើម្បីអនុវត្តន៍លក្ខណវិនិច្ឆ័យដូចបានកំណត់នៅក្នុងដីកានេះ សញ្ញាណនៃសាច់ញាតិជិតស្និទ្ធមិនគ្រាន់តែរាប់បញ្ចូលឪពុកម្តាយនិងកូនទេ ប៉ុន្តែថែមទាំងទំនាក់ទំនងជាប្តី/ប្រពន្ធ និងបងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ផងដែរ[១២]។ ការសន្មតទុកជាមុន នឹងត្រូវចាត់ទុកថាមិនអាចជំទាស់/កែប្រែបាននៅក្នុងស្ថានភាពដូចខាងក្រោម៖

---

[៨] ក្នុងគោលបំណងរបស់ដីកានេះ ការទទួលរងព្យសនកម្មដោយជនរងគ្រោះផ្ទាល់អាចរួមមានទាំងការទទួលរងព្យសនកម្មផ្នែករូបរាងកាយ ការទទួលរងផ្នែកផ្លូវចិត្ត និង/ឬសម្ភារៈ

[៩] ក្រមពហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មាត្រា១៣ ចែងថា " ព្យសនកម្មអាចជាការខូចខាតផ្នែកសម្ភារៈ រាងកាយ ឬក៏ផ្លូវចិត្ត"

[១០] មើលជាអាទិ៍ សាលក្រមរឿងក្តី Lubanga Dyilo របស់សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ កឋាខណ្ឌទី៤៩, និងកឋាខណ្ឌទី៣២ នៃសាលក្រមចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ នៃរឿងក្តីដដែល។

[១១] រឿងក្តី ***Valle-Jaramillo et. al*** នៃតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស(Cour interaméri caine des droit de l'Homme) ចុះថ្ងៃ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ កឋាខណ្ឌ១១៩ និង៣២ នៃសាលក្រម។

[១២] មើលជាអាទិ៍ សេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានទាក់ទងនឹងជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច (សេចក្តីសម្រេចរបស់អង្គការសហប្រជាតិលេខ៤០/៣៤ អនុម័តថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥); គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំទាក់ទងទៅនឹងសិទ្ធិក្នុងការប្តឹង និងការទាមទារសំណង នៃជនរងគ្រោះនៃការរំលោភបំពានទាំងឡាយណាដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្សជាអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងច្បាប់មនុស្សជាតិជាអន្តរជាតិ (សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ៦០/១៤៧ អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ កឋាខ័ណ្ឌទី៨; កឋាខណ្ឌទី៣២ នៃសាលក្រម នៃរឿងក្តី ***Lubanga Dyilo*** នៅតុលាការព្រហ្មទណ្ឌអន្តរជាតិថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨; រឿងក្តី ***Street Children*** នៅតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សថ្ងៃទី (Cour interaméricaine des droit de l'Homme)២៦ ខែឧសភា ឆ្នាំ២០០១ កឋាខ័ណ្ឌទី៦៨; រឿងក្តី ***Myrna Mack Chang*** នៅតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស(Cour interaméricaine des droit de l'Homme)ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ កឋាខ័ណ្ឌទី២៣៣, ២៤៤។

១. ក្នុងករណីដែលជនរងគ្រោះផ្ទាល់បានស្លាប់ ឬបាត់ខ្លួនបណ្តាលមកពីអំពើមួយដែលស្ថិតនៅក្រោមការស៊ើបសួរ[១៣]។

២. ក្នុងករណីដែលជនរងគ្រោះផ្ទាល់ត្រូវបានជម្លៀសដោយបង្ខំ និងត្រូវបានបំបែកចេញពីសាច់ញាតិជិតស្និទ្ធដែលបណ្តាលមកពីអំពើណាមួយដែលស្ថិតនៅក្រោមការស៊ើបសួរ ដែលការបំបែកចេញពីគ្នានេះបង្កឲ្យសមាជិកសាច់ញាតិជិតស្និទ្ធទទួលរងនូវការឈឺចាប់ដែលឈានដល់កម្រិតទទួលយកបានថាជាការទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គល។

ខ) ក្នុងករណីដែលជនរងគ្រោះផ្ទាល់ត្រូវបានរៀបការដោយបង្ខំ ក្នុងកាលៈទេសៈបែបនេះកំណត់បានថាឪពុកម្តាយរបស់ពួកគេ ប្តីឬប្រពន្ធមុនរបស់ពួកគេ កូនៗមុនរបស់ពួកគេទទួលរងនូវកម្រិតព្យសនកម្មផ្លូវចិត្តដែលមិនអាចជៀសរួច។

គ) សហចៅក្រមស៊ើបអង្កេតយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង អំពីការនឹងវាយតម្លៃរបស់ខ្លួនថា“*ការបង្ហាញការខូចខាតដោយផ្ទាល់ទៅលើសមាជិកគ្រួសារសាច់ឆ្ងាយៗពិតជាមានការលំបាកណាស់*[១៤] និងយល់ឃើញថាការសន្មតទុកជាមុនជាធម្មតាកើតមានចំពោះសមាជិកគ្រួសារសាច់ឆ្ងាយ (ជីដូនជីតា ពូមីង ក្មួយប្រុសក្មួយស្រី បួនជីដូនមួយ សាច់ញាតិរបស់ជនរងគ្រោះផ្ទាល់)[១៥] ។ នៅក្នុងសម្មតិកម្មនេះ សហចៅក្រមស៊ើបអង្កេតនឹងពិនិត្យទៅតាមករណីនីមួយៗ ប្រសិន

---

[១៣] មើលជាអាទិ៍ ស្ថានការណ៍នៅប្រទេសកុងហ្គោ (Congo) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិថ្ងៃទី ៣១ ខែមករា ឆ្នាំ២00៨ កថខណ្ឌកំណែទី២៣ដល់២៥; កឋាខ័ណ្ឌទី៣៥ នៃសេចក្តីសម្រេចនៃរឿងក្តី ***Ahmad Harun et al*** របស់តុលាការព្រហ្មទណ្ឌអន្តរជាតិថ្ងៃទី៦ ខែធ្នូ ឆ្នាំ២00៧; កឋាខ័ណ្ឌទី១៣0 ដល់១៣៤ នៃសេចក្តីសម្រេចទៅលើរឿងក្តី ***Kurt*** នៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(CEDH) ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៨; កឋាខ័ណ្ឌទី១២៣ នៃរឿងក្តី ***La Cantuta*** Cour interaméricaine នៃសិទ្ធិមនុស្សទាក់ទងនឹងគុណូបការៈ សំណង និងតម្លៃ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២00៣; រឿងក្តី ***Myrna Mack Chang*** នៅតុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្ស(Cour interaméricaine des droit de l'Homme)ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២00៣ដែលលើកឡើងស្របនឹងគំនិតចៅក្រម Sergio Garcia-Ramirez នៅក្នុងកឋាខ័ណ្ឌទី៥៦, ៥៧,៥៩,៦0,៦១,៦២។ រឿងក្តី*Cakici* នៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (CEDH) ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ សំណុំរឿងលេខ២៣៦៥៧/៩៤; កឋាខ័ណ្ឌទី១៤៧នៃ រឿងក្តី*Bamaca Velasquez* នៃតុលាការរ៉ុបស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២000 (CEDH) និងបន្តមកទៀតកឋាខណ្ឌទី១១៤ដល់ ១១៦ នៃដីកាបស់រឿងក្តី ***Blake*** នៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (CEDH)ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៨។

[១៤] កឋាខ័ណ្ឌទី៦៤៣ នៃសាលក្រមរបស់អង្គជំនុំសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងរឿងក្តីកាំងហ្គេចអ៊ាវ ហៅឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0។

[១៥] ជាទូទៅនៅប្រទេសបារាំង ការទទួលស្គាល់ទៅលើការទទួលរងព្យសនកម្មផ្លូវចិត្តដោយមិនផ្ទាល់តាមរយៈសាច់ញាតិត្រូវបានកំណត់ចាប់តាំងពីឆ្នាំ១៩២៣ (Cass, Chambre civile, 13 février 1923) ដោយតុលាការកំពូលរបស់ប្រទេសបារាំង។ ចាប់តាំងពីពេលនោះមក ចំណងនៃសេចក្តីស្រឡាញ់មិនត្រូវបានគេទទួលស្គាល់គ្រប់បុគ្គលទាំងអស់នោះទេ លើកលែងតែបុគ្គលមួយចំនួនដែលមានចំណងនៃ

00603436



បើភស្តុតាងគ្រប់គ្រាន់ដែលអាចបង្ហាញថាវាមានចំណងនៃសេចក្តីស្រឡាញ់ ឬចំណងអ្នកនៅក្នុងបន្ទុករវាងអ្នកដាក់ពាក្យសុំ និងជនរងគ្រោះផ្ទាល់។ លើសពីនេះ សច្ចាធារណ៍នឹងត្រូវបានចាត់ទុកដូចជាការកំណត់ដ៏ច្បាស់លាស់នៅក្នុងស្ថានភាពដែលថា ជនរងគ្រោះផ្ទាល់ត្រូវបានស្លាប់ ឬក៏បាត់ខ្លួនដែលបណ្តាលមកពីអំពើណាមួយដែលស្ថិតក្រោមការស៊ើបអង្កេត។

ឃ) ព្យសនកម្មផ្លូវចិត្តបានលើកឡើងដោយអ្នកដាក់ពាក្យសុំ ដែលពាក់ព័ន្ធនឹងអំពើមនុស្សឃាត ឬការបាត់ខ្លួនសាច់ញាតិគឺមានលក្ខណៈងាយស្រួលក្នុងការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីជាងក្នុងករណីនៃការរៀបការដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ ទឡ្ហីករណ៍ដូចគ្នាត្រូវតែយកមកអនុវត្តន៍ផងដែរ ក្នុងករណីដែលអ្នកស្នើសុំគឺជាសាក្សីធម្មតាចំពោះអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេតគឺថា៖ ព្យសនកម្មផ្លូវចិត្តបង្កប់នូវកម្រិត និងលក្ខណៈដោយឡែកផ្ទុយពីការឈឺចាប់ផ្នែកអារម្មណ៍ដែលសាក្សីធម្មតាត្រូវបង្ហាញ ហើយពាក្យស្នើសុំរបស់គេនឹងត្រូវបដិសេធចោល លើកលែងតែថាសាក្សីនោះបង្ហាញថាបានឃើញអង្គហេតុនៃអំពើហឹង្សា និងអំពើដែលមានលក្ខណៈតក់ស្លុតជាខ្លាំង។

## iii) ទំនាក់ទំនងហេតុ និងបច្ច័យរវាងព្យសនកម្ម និងឧក្រិដ្ឋកម្ម ទាំងឡាយដែលបានចោទប្រកាន់លើជនត្រូវចោទ

១៦. ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំចាំបាច់ត្រូវតែបង្ហាញពីព្យសនកម្មដែលកើតមានឡើងដោយផ្ទាល់ពីអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[១៦]។

---

សេចក្តីស្រឡាញ់នោះមានលក្ខណៈជ្រាលជ្រៅជាមួយនឹងជនរងគ្រោះ ទោះបីថាស្ថិតក្រៅក្របខណ្ឌនៃច្បាប់ក៏ដោយ។ មើលផងដែរនូវសាលក្រមរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (CEDH) កឋាខណ្ឌ៦៣ នៃរឿងក្តី *Yasa* ; កឋាខ័ណ្ឌទី១២៨, ១៣៩,នៃសាលក្រមរបស់តុលាការអន្តរទ្វីបអាមេរិកស្តីពីសិទ្ធិមនុស្សទាក់ទងនឹងរឿងក្តី*Kawas-Fernandez* ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩; កឋាខ័ណ្ឌទី៩៨ នៃសាលក្រមរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សទាក់ទងនឹងរឿងក្តី*Cakici* ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៩។

[១៦] មើលជាអាទិ៍ សេចក្តីប្រកាសថ្លែងការណ៍ចេញដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការស៊ើបសួរនៅក្នុងសំណុំរឿង០០២/១៩-០៩-២០០៧-ECCC-OCIJ និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី; មើលផងដែរនូវ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៦៤ មាត្រា១៣ដែលចែងថា "មិនមែនគ្រាន់តែត្រូវឲ្យមានជាមួយគ្នានូវបទល្មើសលើច្បាប់ព្រហ្មទណ្ឌ ហើយនិងការខូចខាតដែលត្រូវបណ្តាលឲ្យមានប៉ុណ្ណោះទេ ត្រូវឲ្យមានថែមទៀតផងរវាងបទទាំងពីរនេះនូវការទាក់ទិនគ្នាពីហេតុទៅផល ឬសេចក្តីម្យ៉ាងទៀតថា ត្រូវឲ្យមានការខូចខាតនេះជាលទ្ធផលផ្ទាល់របស់បទល្មើសហើយត្រូវឲ្យកើតមានមែនទែនជាពិតប្រាកដ"។

១៧. លក្ខណៈវិនិច្ឆ័យនេះមានលក្ខណៈជាក់លាក់ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍។ នៅចំពោះមុខ អ.វ.ត.ក ដោយផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[១៧] ជនរងគ្រោះដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចដំណើរការបណ្តឹងអាជ្ញាបានឡើយគឺថាគ្រាន់តែអាចធ្វើឡើងតាមផ្លូវអន្តរាគមន៍ ដោយជនរងគ្រោះគ្រាន់តែអាចចូលរួមដំណើរការនីតិវិធីដោយសារការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមិនពង្រីកការចូលរួមដំណើរការនីតិវិធីឱ្យហួសពីបណ្តឹងលើអង្គហេតុ (la saisine *in rem*) ដែលប្តឹងមកសហចៅក្រមស៊ើបអង្កេតដែលបានកំណត់ដោយសហព្រះរាជអាជ្ញា។

១៨. ដូចនេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកម្រិតនៅក្នុងលក្ខខ័ណ្ឌដែលពាក្យស្នើសុំមិនអាចប្តឹងទៅលើអង្គហេតុថ្មីនៅក្នុងដំណាក់កាលស៊ើបសួរឡើយ ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញាទេនោះ[១៨]។

១៩. ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន វាចាំបាច់ដែលថាអ្នកដាក់ពាក្យសុំត្រូវតែបង្ហាញពីព្យសនកម្មរបស់ខ្លួនដែលបណ្តាលមកពីអង្គហេតុណាមួយដែលបានបើកការស៊ើបសួរហើយតែប៉ុណ្ណោះ។

## ខ. ការទទួលយកបាននៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

២០. អនុលោមតាមអ្វីដែលបកស្រាយខាងលើ សហចៅក្រមស៊ើបអង្កេតសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ទៅតាមពាក្យពេចន៍ដូចតទៅនេះ៖

### i) ភស្តុតាងអំពីអត្តសញ្ញាណរបស់ដើមបណ្តឹង

២១. អ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ (ដប់នាក់)[១៩] មិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីអត្តសញ្ញាណនោះទេ។ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា

[១៧] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ មាត្រា១៣៨ ដល់មាត្រា១៤២៖បណ្តឹងដោយមានការសុំតាំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[១៨] មើលយុត្តិសាស្ត្រដែលកើតមាននៅតុលាកំពូលប្រទេសបារាំងចុះថ្ងៃទី ២៥ មិថុនា ឆ្នាំ១៩៣៧ **Cass. crim. [25 juin 1937] publié au Bull. crim. n°134 ; Cass. crim.**; យុត្តិសាស្ត្ររបស់តុលាការកំពូលចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៦១ **Cass. crim. [25 janvier 1961] publié au Bull. crim. n°44** ; យុត្តិសាស្ត្ររបស់តុលាការកំពូលចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨៩ **Cass. crim. [17 mai 1989]** D. 1990 p. 74 note D. Mayer; យុត្តិសាស្ត្ររបស់តុលាការកំពូលចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩១. **[15 janvier 1991] Juris-Data n° 1991-700801 publié au Bull. crim. n° 24**; យុត្តិសាស្ត្ររបស់តុលាការកំពូលចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ **Cass. crim. [9 novembre. 1995] Juris-Data n°1995-003776 publié au Bull. crim. n° 345**.

[១៩] មើលឧបសម្ព័ន្ធ៣ (១) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយក ៖ *គ្មានភស្តុតាងបញ្ជាក់ពីអត្តសញ្ញាណ*

អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត បានផ្តល់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ និងប្រាប់ពីអាសយដ្ឋាននៅកម្ពុជា។ តាមរយៈនេះ សហចៅក្រមស៊ើបអង្កេតចាត់ទុកថាអត្តសញ្ញាណរបស់ពួកគេត្រូវបានបង្ហាញហើយ។

*ii) អត្ថិភាពនៃព្យសនកម្ម*

២២. បន្ថែមពីលើនេះសហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា បណ្តាអ្នកប្តឹងទាំងអស់បានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តបានថាពួកគេបានទទួលរងព្យសនកម្មជាលក្ខណៈបុគ្គលនៅក្នុងយុត្តាធិការនៃអ.វ.ត.ក។

២៣. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា បណ្តាអ្នកប្តឹងភាគច្រើនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យជឿទុកចិត្តបានថាពួកគេបានទទួលរងព្យសនកម្មជាលក្ខណៈបុគ្គលនៅក្នុងយុត្តាធិការនៃអ.វ.ត.ក។២៤. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៧នាក់ (ដប់ប្រាំពីរនាក់)[២០] ពុំបានបង្ហាញភស្តុតាងអំពីទំនាក់ទំនងញាតិជាមួយនឹងជនរងគ្រោះផ្ទាល់នោះទេ ហើយទំនាក់ទំនងហេតុ និងបច្ច័យជាសារវ័ន្តរវាងព្យសនកម្មផ្សេងៗទៀតដែលបានលើកឡើង ទៅនឹងអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេតក៏មិនបានបង្ហាញដែរ។

២៤. សហចៅក្រមស៊ើបអង្កេតយល់ឃើញផងដែរថា មានអ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៦នាក់ (ប្រាំមួយនាក់)[២១] មិនបានបង្ហាញអំពីទំនាក់ទំនងនៃសេចក្តីស្រឡាញ់ ឬភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះដែលអនុញ្ញាតឱ្យកំណត់បាននូវលក្ខណៈនៃព្យសនកម្មផ្លូវចិត្តស្របទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេតបានទេ។ លើសពីនេះ ទំនាក់ទំនងហេតុ និងបច្ច័យជាសារវ័ន្តរវាងព្យសនកម្មផ្សេងៗទៀតដែលបានលើកឡើង ទៅនឹងអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេតក៏មិនបានបង្ហាញដែរ។

---

[២០] មើលឧបសម្ព័ន្ធ៣ (៣) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយក ៖ *គ្មានទំនាក់ទំនងសាច់ញាតិដោយផ្ទាល់ជាមួយជនរងគ្រោះ*

[២១] មើលឧបសម្ព័ន្ធ៣ (៥) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយ ៖ *កម្រិតនៃព្យសនកម្មផ្លូវចិត្តមិនទទួលយកបាន , (៦) ព្យសនកម្មពុំមានទាក់ទំនងទៅនឹងអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត*

***iii) ចំនោក់ចំនួនទោងព្យសនកម្ម និងអំពើល្មើសដែលបានប្រកាន់ប្រឆាំងនឹងជនត្រូវចោទ***

២៥. ក្រោយពីបានពិនិត្យព័ត៌មានផ្សេងៗមកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៩៨ នាក់ (មួយរយកៅសិបប្រាំបីនាក់)[២២] ត្រូវបានទទួលយក។ ពោលគឺជាអ្នកប្តឹងទាំងឡាយណាដែលបានភ្ជាប់មកជាមួយនូវភស្តុតាងគ្រប់គ្រាន់ហើយដែលក្រោយពីការពិនិត្យជាបឋមអាចឲ្យយើងឃើញថាព្យសនកម្មរបស់គាត់គឺចេញពីផលវិបាកដោយផ្ទាល់ទៅនឹងអំពើដែលជាកម្មវត្ថុនៃការស៊ើបអង្កេតតាមផ្លូវតុលាការដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ បញ្ជីនេះបែងចែងទៅតាមប្រភេទនៃព្យសនកម្មដែលលើកឡើងដោយអ្នកដាក់ពាក្យបណ្តឹង។ អ្នកដាក់ពាក្យបណ្តឹងម្នាក់អាចមាននៅក្នុងផ្នែកច្រើនប្រសិនជាគាត់ត្រូវបានទទួលស្គាល់ច្រើនករណីដូចជា៖

*ព្រលានយន្តហោះកំពង់ឆ្នាំង/ខេត្តកំពង់ឆ្នាំង*

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ការដ្ឋានទំនប់១មករា/ខេត្តកំពង់ធំ*

-អ្នកប្តឹងចំនួន០២នាក់ (ពីរនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

[២២] មើលឧបសម្ព័ន្ធ២: ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលយក...

00603440



*មន្ទីរស២៤(ព្រៃស)/ភ្នំពេញ*

-អ្នកប្តឹងចំនួន០២នាក់ (ពីរនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*កន្លែងសម្លាប់មនុស្សស្ទឹងត្រួច/ខេត្តកំពង់ចាម*

-អ្នកប្តឹងចំនួន០៤នាក់ (បួននាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៦៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*មន្ទីរស-២១/ភ្នំពេញ*

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៩-៥៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន១៦នាក់ (ដប់ប្រាំមួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤៩-៥៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ការផ្លាស់កន្លែងប្រជាជនចេញពីភ្នំពេញ/ដំណាក់កាលទី១*

-អ្នកប្តឹងចំនួន២៩នាក់ (ម្ភៃប្រាំបួននាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្ម

00603441



ទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៣៧-៣៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន៤៥នាក់ (សែសិបប្រាំនាក់)បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៣៧-៣៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ការផ្លាស់កន្លែងប្រជាជនពីភូមិភាគកណ្តាល និងភូមិភាគនិរតីនៃប្រទេស ទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ/ដំណាក់កាលទី២*

-អ្នកប្តឹងចំនួន១៤នាក់ (ដប់បួននាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤០-៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន០៤នាក់ (ប្រាំបួននាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤០-៤១នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ការផ្លាស់កន្លែងប្រជាជនពីភូមិភាគបូព៌ា/ដំណាក់កាលទី៣*

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន០៣នាក់ (បីនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤២នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ប្រព្រឹត្តកម្មលើពុទ្ធសាសនិក*

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន០៤នាក់ (បួននាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៧២នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ប្រព្រឹត្តកម្មលើជនជាតិភាគតិចចាម*

-អ្នកប្តឹងចំនួន២៦នាក់ (ម្ភៃប្រាំមួយនាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងកឋាខ័ណ្ឌ៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និងកឋាខ័ណ្ឌ៣-២៣នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម (D196) ។

-អ្នកប្តឹងចំនួន១២នាក់ (ដប់ពីរនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែង នៅក្នុងកឋាខ័ណ្ឌ៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និងកឋាខ័ណ្ឌ៣-២៣នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម (D196) ។

*ការបោសសម្អាតខ្មាំង*

-អ្នកប្តឹងចំនួន០១នាក់ (មួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែងនៅក្នុង កឋាខ័ណ្ឌ៤២ និង៧១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

-អ្នកប្តឹងចំនួន៥៣នាក់ (ហាសិបបីនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមានចែង នៅក្នុងកថាខ័ណ្ឌ៤២ និង៧១នៃដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។

*ការរៀបការដោយបង្ខំ*

-អ្នកប្តឹងចំនួន៥៤នាក់ (ហាសិបបួននាក់) បានទទួលរងព្យសនកម្មក្នុងនាមជាជនរងគ្រោះផ្ទាល់ជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដូចដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា D146/3, D146/4 និងD146/5។

-អ្នកប្តឹងចំនួន១១នាក់ (ដប់មួយនាក់) បានទទួលរងព្យសនកម្មផ្លូវចិត្តជាលក្ខណៈបុគ្គលដែលបណ្តាលមកពីផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តទៅលើសមាជិកគ្រួសាររបស់គាត់ម្នាក់ ឬច្រើននាក់ដូចដែលមាន ចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា D146/3, D146/4 និង D146/5។

២៦. ផ្ទុយពីនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទំនាក់ទំនងហេតុផលចាំបាច់រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុដែលស្ថិតក្នុងការស៊ើបអង្កេត មិនត្រូវបានបង្ហាញដោយអ្នកប្តឹងចំនួន១៧៥នាក់ (មួយរយចិតសិបប្រាំនាក់)[២៣] នៅក្នុងលក្ខខ័ណ្ឌដែលអង្គហេតុបានលើកឡើងគឺសរុបមកផ្សេងពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរបន្ថែម ព្រមទាំងយល់ឃើញថាគ្មានកាលៈទេសៈណាមួយដែលអនុញ្ញាតិឱ្យយើងទទួលយកថាជាទំនាក់ទំនងផ្ទាល់រវាងព្យសនកម្មដែលបានលើកឡើងនិងបទល្មើសដែលបានប្តឹងមកនោះទេ។

[២៣] *មើលឧបសម្ព័ន្ធ៣(៦): ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយក៖ព្យសនកម្មពុំមានទាំនក់ទំនងទៅនឹងអង្គហេតុដែលស្ថិតក្រោមការស៊ើបអង្កេត*

00603444



២៧. ជាចុងក្រោយមានអ្នកប្ដឹងចំនួន៨០នាក់ (ប៉ែតសិបនាក់)[២៤] មិនបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរវាងពាក្យបណ្ដឹងជាមួយនឹងវិធាន២៣ ស្ទួន(១) និង(៤)នោះទេ។

## អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត

**កត់សំគាល់** មរណភាពនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ**07-VU-00016 (D22/1272), 08-VU-00740 (D22/2634), 08-VU-01340 (D22/1331), 09-VU-00344 (D22/1732)**, និងលេខ **09-VU-03422 (D22/2417)** និងដោយមូលហេតុថាមិនមានទាយាទណាមួយបន្តបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគាត់ បណ្ដឹងទាំងនេះត្រូវបានរំលត់។

**សម្រេចថា** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខសម្គាល់

07-VU-00004 (D22/0050), 07-VU-00015 (D22/1264), 07-VU-00018 (D22/0627), 07-VU-00020 (D22/1280), 07-VU-00100 (D22/0623), 07-VU-00254 (D22/2614), 07-VU-00259 (D22/0622), 07-VU-00409 (D22/0538), 08-VU-00007 (D22/1286), 08-VU-00152 (D22/0219), 08-VU-00162 (D22/0041), 08-VU-00194 (D22/1318), 08-VU-00232 (D22/1319), 08-VU-00233 (D22/1309), 08-VU-00234 (D22/0016), 08-VU-00235 (D22/1296), 08-VU-00250 (D22/1374), 08-VU-00645 (D22/0486), 08-VU-00646 (D22/1020), 08-VU-00647 (D22/1342), 08-VU-00649 (D22/1341), 08-VU-00650 (D22/1340), 08-VU-00651 (D22/0514), 08-VU-00652 (D22/0163), 08-VU-00653 (D22/0479), 08-VU-00654 (D22/0164), 08-VU-00702 (D22/0882), 08-VU-00704 (D22/0884), 08-VU-00721 (D22/2629), 08-VU-00726 (D22/0737), 08-VU-00727 (D22/2039), 08-VU-00731 (D22/0592), 08-VU-00732 (D22/0591), 08-VU-00734 (D22/0986), 08-VU-00737 (D22/1867), 08-VU-00739 (D22/1870), 08-VU-00741 (D22/1682), 08-VU-01254 (D22/0971), 08-VU-01255 (D22/0972), 08-VU-01316 (D22/2638), 08-VU-01318 (D22/1014), 08-VU-01323 (D22/1874), 08-VU-01328 (D22/1875), 08-VU-01331 (D22/0598), 08-VU-01332 (D22/1637), 08-VU-01333 (D22/1653), 08-VU-01334 (D22/0480), 08-VU-01335 (D22/1652), 08-VU-01336 (D22/1330), 08-VU-01337 (D22/1345), 08-VU-01338 (D22/1651), 08-VU-01352 (D22/0625), 08-VU-01355 (D22/2048), 08-VU-01356 (D22/0624), 08-VU-01359 (D22/1857), 08-VU-01524 (D22/2053), 08-VU-01526 (D22/0051), 08-VU-01584 (D22/2032), 08-VU-01901 (D22/2651), 08-VU-01902 (D22/2652), 08-VU-01909 (D22/1059), 08-VU-01935 (D22/1947), 08-VU-02244 (D22/0214), 08-VU-02248

---

[២៤] *មើលឧបសម្ព័ន្ធ៣(៤): ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានទទួលយក៖ពុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរវាងពាក្យបណ្ដឹងជាមួយនឹងវិធាន២៣ ស្ទួន (១) និង(៤)*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៧១19
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

(D22/0868), 08-VU-02252 (D22/2662), 08-VU-02253 (D22/0255), 08-VU-02254
(D22/0254), 09-VU-00310 (D22/2013), 09-VU-00311 (D22/1984), 09-VU-00312
(D22/1983), 09-VU-00313 (D22/2016), 09-VU-00314 (D22/1471), 09-VU-00317
(D22/2018), 09-VU-00318 (D22/2015), 09-VU-00327 (D22/1818), 09-VU-00334
(D22/1816), 09-VU-00335 (D22/1817), 09-VU-00556 (D22/2005), 09-VU-00557
(D22/2008), 09-VU-00764 (D22/1260), 09-VU-00766 (D22/1683), 09-VU-00822
(D22/1680), 09-VU-00824 (D22/1482), 09-VU-00827 (D22/0306), 09-VU-00829
(D22/0316), 09-VU-00830 (D22/0546), 09-VU-01100 (D22/0891), 09-VU-01594
(D22/0511), 09-VU-01595 (D22/0503), 09-VU-01596 (D22/0532), 09-VU-01597
(D22/0530), 09-VU-01989 (D22/2972), 09-VU-01990 (D22/2973), 09-VU-01991
(D22/2974), 09-VU-01992 (D22/2975), 09-VU-01993 (D22/2976), 09-VU-02075
(D22/3036), 09-VU-02165 (D22/2204), 09-VU-02166 (D22/3080), 09-VU-02168
(D22/3081), 09-VU-02189 (D22/3101), 09-VU-02195 (D22/3107), 09-VU-02490
(D22/3132), 09-VU-02494 (D22/2270), 09-VU-02495 (D22/2271), 09-VU-02496
(D22/2272), 09-VU-02497 (D22/2273), 09-VU-03406 (D22/2401), 09-VU-03411
(D22/2406), 09-VU-03418 (D22/2413), 09-VU-03419 (D22/2414), 09-VU-03420
(D22/2415), 09-VU-03421 (D22/2416), 09-VU-03424 (D22/2419), 09-VU-03425
(D22/2420), 09-VU-03437 (D22/3155), 09-VU-03438 (D22/3156), 09-VU-03439
(D22/3157), 09-VU-03440 (D22/3158), 09-VU-03441 (D22/3159), 09-VU-03463
(D22/3172), 09-VU-03536 (D22/3233), 09-VU-03537 (D22/3234), 09-VU-03538
(D22/3235), 09-VU-03539 (D22/3236), 09-VU-03540 (D22/3237), 09-VU-03541
(D22/3238), 09-VU-03542 (D22/3239), 09-VU-03543 (D22/3240), 09-VU-03544
(D22/3241), 09-VU-03553 (D22/3247), 09-VU-03584 (D22/3278), 09-VU-03598
(D22/3291), 09-VU-03599 (D22/3292), 09-VU-03603 (D22/3296), 09-VU-03607
(D22/3299), 09-VU-03619 (D22/3308), 09-VU-03620 (D22/3309), 09-VU-03674
(D22/3339), 09-VU-03677 (D22/3342), 09-VU-03679 (D22/3344), 09-VU-03680
(D22/3345), 09-VU-03682 (D22/3347), 09-VU-03691 (D22/3356), 09-VU-03694
(D22/3359), 09-VU-03697 (D22/3362), 09-VU-03698 (D22/3363), 09-VU-03704
(D22/3369), 09-VU-03711 (D22/3373), 09-VU-03716 (D22/3376), 09-VU-03717
(D22/3377), 09-VU-03736 (D22/3390), 09-VU-03741 (D22/3394), 09-VU-03743
(D22/3396), 09-VU-03744 (D22/3397), 09-VU-03745 (D22/3398), 09-VU-03746
(D22/3399), 09-VU-04157 (D22/3562), 09-VU-04158 (D22/3563), 09-VU-04159
(D22/3564), 09-VU-04160 (D22/3565), 09-VU-04162 (D22/3567), 09-VU-04163
(D22/3568), 09-VU-04165 (D22/3570), 09-VU-04166 (D22/3571), 09-VU-04169
(D22/3574), 09-VU-04170 (D22/3575), 09-VU-04171 (D22/3576), 09-VU-04213
(D22/2476), 09-VU-04214 (D22/2477), 10-VU-00009 (D22/2494), 10-VU-00010
(D22/2495), 10-VU-00011 (D22/3681), 10-VU-00118 (D22/3713), 10-VU-00119
(D22/3714), 10-VU-00121 (D22/2547), 10-VU-00123 (D22/2548), 10-VU-00126
(D22/3718), 10-VU-00128 (D22/2550), 10-VU-00132 (D22/2553), 10-VU-00139
(D22/3725), 10-VU-00140 (D22/3726), 10-VU-00145 (D22/2560), 10-VU-00147
(D22/2562), 10-VU-00150 (D22/2564), 10-VU-00151 (D22/2565), 10-VU-00157
(D22/2568), 10-VU-00159 (D22/2570), 10-VU-00169 (D22/3733), 10-VU-00170
(D22/3734), 10-VU-00171 (D22/2577), 10-VU-00176 (D22/2581), 10-VU-00866
(D22/3879), 10-VU-00889 (D22/3899), 10-VU-00890 (D22/3900), 10-VU-00891
(D22/3901), 10-VU-00968 (D22/3967) និងលេខ 10-VU-00969 (D22/3968) ត្រូវបានទទួលយក។

00603446



**សម្រេចថា** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតរួមមានលេខសម្គាល់៖

07-VU-00002 (D22/1271), 07-VU-00003 (D22/1266), 07-VU-00017 (D22/1276), 07-VU-00019 (D22/1273), 07-VU-00024 (D22/1274), 07-VU-00025 (D22/1283), 07-VU-00026 (D22/1282), 07-VU-00027 (D22/1015), 07-VU-00118 (D22/2608), 07-VU-00378 (D22/2621), 08-VU-00008 (D22/1300), 08-VU-00009 (D22/1016), 08-VU-00193 (D22/1316), 08-VU-00195 (D22/1293), 08-VU-00236 (D22/1393), 08-VU-00637 (D22/1629), 08-VU-00655 (D22/1709), 08-VU-00699 (D22/1023), 08-VU-00700 (D22/1024), 08-VU-00701 (D22/0904), 08-VU-00703 (D22/0883), 08-VU-00705 (D22/0924), 08-VU-00722 (D22/0734), 08-VU-00723 (D22/1871), 08-VU-00724 (D22/0735), 08-VU-00725 (D22/0736), 08-VU-00728 (D22/0738), 08-VU-00729 (D22/1046), 08-VU-00730 (D22/2630), 08-VU-00733 (D22/2631), 08-VU-00735 (D22/2632), 08-VU-00736 (D22/2633), 08-VU-00738 (D22/0987), 08-VU-00742 (D22/0988), 08-VU-01199 (D22/0456), 08-VU-01200 (D22/1431), 08-VU-01238 (D22/1402), 08-VU-01239 (D22/1403), 08-VU-01240 (D22/1407), 08-VU-01241 (D22/1406), 08-VU-01242 (D22/1405), 08-VU-01243 (D22/1389), 08-VU-01244 (D22/1377), 08-VU-01245 (D22/1369), 08-VU-01246 (D22/1364), 08-VU-01247 (D22/1388), 08-VU-01248 (D22/1371), 08-VU-01249 (D22/1863), 08-VU-01250 (D22/0970), 08-VU-01251 (D22/0965), 08-VU-01317 (D22/1428), 08-VU-01320 (D22/1636), 08-VU-01321 (D22/0911), 08-VU-01322 (D22/0912), 08-VU-01324 (D22/1878), 08-VU-01325 (D22/0599), 08-VU-01326 (D22/1873), 08-VU-01327 (D22/0913), 08-VU-01329 (D22/2639), 08-VU-01330 (D22/1862), 08-VU-01341 (D22/1635), 08-VU-01349 (D22/0916), 08-VU-01350 (D22/2047), 08-VU-01351 (D22/0917), 08-VU-01353 (D22/0918), 08-VU-01354 (D22/0975), 08-VU-01357 (D22/2640), 08-VU-01358 (D22/2641), 08-VU-01363 (D22/0976), 08-VU-01897 (D22/0179), 08-VU-01903 (D22/0180), 08-VU-01904 (D22/0181), 08-VU-01905 (D22/1865), 08-VU-01906 (D22/2653), 08-VU-01907 (D22/0182), 08-VU-01908 (D22/0183), 08-VU-01910 (D22/1060), 08-VU-01911 (D22/1061), 08-VU-01912 (D22/1062), 08-VU-01913 (D22/0947), 08-VU-01915 (D22/0948), 08-VU-01916 (D22/0949), 08-VU-02245 (D22/0869), 08-VU-02246 (D22/2660), 08-VU-02247 (D22/0115), 08-VU-02249 (D22/2661), 08-VU-02250 (D22/1859), 08-VU-02251 (D22/0867), 09-VU-00315 (D22/1472), 09-VU-00316 (D22/1473), 09-VU-00323 (D22/1793), 09-VU-00324 (D22/1802), 09-VU-00343 (D22/1820), 09-VU-00345 (D22/1813), 09-VU-00763 (D22/0548), 09-VU-00765 (D22/1544), 09-VU-00820 (D22/1453), 09-VU-00821 (D22/1452), 09-VU-00823 (D22/1663), 09-VU-00825 (D22/1483), 09-VU-00826 (D22/1647), 09-VU-00828 (D22/0547), 09-VU-02064 (D22/3025), 09-VU-02065 (D22/3026), 09-VU-02187 (D22/3099), 09-VU-02188 (D22/3100), 09-VU-02190 (D22/3102), 09-VU-02191 (D22/3103), 09-VU-02192 (D22/3104), 09-VU-02193 (D22/3105), 09-VU-02200 (D22/3111), 09-VU-02201 (D22/3112), 09-VU-02491 (D22/2267), 09-VU-02492 (D22/2268), 09-VU-02493 (D22/2269), 09-VU-02498 (D22/2274), 09-VU-02500 (D22/2276), 09-VU-03404 (D22/2400), 09-VU-02499 (D22/2275), 09-VU-02504 (D22/2280), 09-VU-02505 (D22/3133), 09-VU-02506 (D22/3134), 09-VU-02507 (D22/2281), 09-VU-02508 (D22/2282), 09-VU-02509 (D22/2283), 09-VU-02510 (D22/3135), 09-VU-02511 (D22/3136), 09-VU-02512 (D22/2284), 09-VU-03403 (D22/2399), 09-VU-03407 (D22/2402), 09-VU-03408 (D22/2403), 09-VU-03409 (D22/2404), 09-VU-03410 (D22/2405), 09-VU-03412 (D22/2407), 09-VU-03413 (D22/2408), 09-VU-03414 (D22/2409), 09-VU-03415 (D22/2410), 09-VU-03416 (D22/2411), 09-VU-03417 (D22/2412), 09-VU-03423 (D22/2418), 09-VU-03555 (D22/3249), 09-VU-03556

00603447



(D22/3250), 09-VU-03557 (D22/3251), 09-VU-03558 (D22/3252), 09-VU-03559
(D22/3253), 09-VU-03560 (D22/3254), 09-VU-03561 (D22/3255), 09-VU-03567
(D22/3261), 09-VU-03580 (D22/3274), 09-VU-03581 (D22/3275), 09-VU-03582
(D22/3276), 09-VU-03583 (D22/3277), 09-VU-03585 (D22/3279), 09-VU-03586
(D22/3280), 09-VU-03587 (D22/3281), 09-VU-03588 (D22/3282), 09-VU-03589
(D22/3283), 09-VU-03596 (D22/3289), 09-VU-03597 (D22/3290), 09-VU-03600
(D22/3293), 09-VU-03601 (D22/3294), 09-VU-03602 (D22/3295), 09-VU-03605
(D22/3297), 09-VU-03606 (D22/3298), 09-VU-03608 (D22/3300), 09-VU-03609
(D22/3301), 09-VU-03610 (D22/3302), 09-VU-03611 (D22/3303), 09-VU-03612
(D22/3304), 09-VU-03613 (D22/3305), 09-VU-03614 (D22/3306), 09-VU-03615
(D22/3307), 09-VU-03667 (D22/3332), 09-VU-03668 (D22/3333), 09-VU-03669
(D22/3334), 09-VU-03670 (D22/3335), 09-VU-03671 (D22/3336), 09-VU-03672
(D22/3337), 09-VU-03673 (D22/3338), 09-VU-03675 (D22/3340), 09-VU-03676
(D22/3341), 09-VU-03678 (D22/3343), 09-VU-03681 (D22/3346), 09-VU-03692
(D22/3357), 09-VU-03693 (D22/3358), 09-VU-03695 (D22/3360), 09-VU-03696
(D22/3361), 09-VU-03699 (D22/3364), 09-VU-03700 (D22/3365), 09-VU-03701
(D22/3366), 09-VU-03702 (D22/3367), 09-VU-03703 (D22/3368), 09-VU-03706
(D22/3370), 09-VU-03708 (D22/2438), 09-VU-03709 (D22/2439), 09-VU-03713
(D22/3994), 09-VU-03714 (D22/3374), 09-VU-03715 (D22/3375), 09-VU-03718
(D22/2440), 09-VU-03719 (D22/2441), 09-VU-03720 (D22/2442), 09-VU-03725
(D22/3380), 09-VU-03726 (D22/3381), 09-VU-03727 (D22/3382), 09-VU-03728
(D22/3383), 09-VU-03730 (D22/3384), 09-VU-03731 (D22/3385), 09-VU-03732
(D22/3386), 09-VU-03733 (D22/3387), 09-VU-03734 (D22/3388), 09-VU-03735
(D22/3389), 09-VU-03737 (D22/3391), 09-VU-03739 (D22/3392), 09-VU-03740
(D22/3393), 09-VU-03742 (D22/3395), 09-VU-03747 (D22/3400), 09-VU-04156
(D22/3561), 09-VU-04161 (D22/3566), 09-VU-04164 (D22/3569), 09-VU-04167
(D22/3572), 09-VU-04168 (D22/3573), 09-VU-04223 (D22/3610), 09-VU-04318
(D22/2487), 09-VU-04330 (D22/2488), 09-VU-04331 (D22/2489), 09-VU-04332
(D22/2490), 09-VU-04333 (D22/2491), 10-VU-00116 (D22/2545), 10-VU-00117
(D22/2546), 10-VU-00120 (D22/3715), 10-VU-00122 (D22/3716), 10-VU-00124
(D22/3717), 10-VU-00125 (D22/2549), 10-VU-00127 (D22/3719), 10-VU-00129
(D22/2551), 10-VU-00130 (D22/3720), 10-VU-00133 (D22/3721), 10-VU-00134
(D22/3722), 10-VU-00135 (D22/2554), 10-VU-00136 (D22/3723), 10-VU-00137
(D22/3724), 10-VU-00138 (D22/2555), 10-VU-00141 (D22/2556), 10-VU-00142
(D22/2557), 10-VU-00143 (D22/2558), 10-VU-00144 (D22/2559), 10-VU-00146
(D22/2561), 10-VU-00149 (D22/2563), 10-VU-00152 (D22/3727), 10-VU-00153
(D22/2566), 10-VU-00154 (D22/3728), 10-VU-00155 (D22/3729), 10-VU-00156
(D22/2567), 10-VU-00158 (D22/2569), 10-VU-00160 (D22/3730), 10-VU-00161
(D22/2571), 10-VU-00162 (D22/2572), 10-VU-00163 (D22/2573), 10-VU-00164
(D22/2574), 10-VU-00165 (D22/3731), 10-VU-00166 (D22/2575), 10-VU-00167
(D22/2576), 10-VU-00168 (D22/3732), 10-VU-00172 (D22/3735), 10-VU-00173
(D22/2578), 10-VU-00174 (D22/2579), 10-VU-00175 (D22/2580), 10-VU-00177
(D22/3736), 10-VU-00178 (D22/2582), 10-VU-00179 (D22/2583), 10-VU-00350
(D22/3775), 10-VU-00384 (D22/3806), 10-VU-00385 (D22/3807), 10-VU-00386
(D22/3808), 10-VU-00387 (D22/3809), 10-VU-00388 (D22/3810), 10-VU-00389
(D22/3811), 10-VU-00390 (D22/3812), 10-VU-00405 (D22/2587), 10-VU-00418
(D22/2588), 10-VU-00419 (D22/2589), 10-VU-00420 (D22/2590), 10-VU-00421
(D22/2591), 10-VU-00422 (D22/2592), 10-VU-00581 (D22/3839), 10-VU-00582
(D22/3840), 10-VU-00966 (D22/3965) និងលេខ 10-VU-00970 (D22/3969) **មិនអាចទទួលយក**

00603448



បានទេ ហើយសម្រេចថា ដោយយោងទៅលើព័ត៌មានជាសារវ័ន្តដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះមាននិយាយពីអង្គហេតុដែលបានកើតឡើងក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅលើទឹកដីកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ ពាក្យសុំទាំងនោះនឹងត្រូវដាក់ចូលទៅក្នុងសំណុំរឿង០០២ (002/19-09-2007-ECCC-OCIJ) ក្រោមទម្រង់ជាពាក្យបណ្តឹងធម្មតា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**Marcel LEMONDE** យូ ប៊ុនឡេង